ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ ០៩៧/ប.ក.កពន.

# ប្រកាស

## ស្តីពី

## ការជ្រើសរើស និងហ្វឹកហ្វឺននាយទាហានសកម្ម ជំនាន់ទី២៥

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធនិងប្តូរឈ្មោះឧទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការដំឡើងសាលានាយទាហានត្បាតពងទៅជាសាលានាយទាហានសកម្ម មានកម្រិតស្មើគ្រឹះស្ថានឧត្តមសិក្សា
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៧៤ សសរ ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការជ្រើសរើសនិស្សិត សិស្សចូល បណ្តុះបណ្តាលនាយទាហាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញប្រកាសរបស់ក្រសួងការពារជាតិលេខ ០៥២/ប្រ.ក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មការជ្រើសរើស និងត្រួតពិនិត្យលក្ខណសម្បត្តិសិក្ខាកាមមកបណ្តុះបណ្តាលនៅក្នុងនិងក្រៅប្រទេស
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ .-**

ត្រូវបានប្រគល់ភារកិច្ចជូនគណៈកម្មការជ្រើសរើស និងត្រួតពិនិត្យលក្ខណសម្បត្តិសិក្ខាកាមមកបណ្តុះបណ្តាលនៅក្នុងនិងក្រៅប្រទេស ជ្រើសរើសនិស្សិត សិស្សចូលហ្វឹកហ្វឺនវគ្គនាយទាហានសកម្មជំនាន់ទី២៥ មានកម្មសិក្សាការីចំនួន១០០(មួយរយ)នាក់ នៅសាលានាយទាហានសកម្ម (ត្បាតពង) ។

**ប្រការ២ ..**

អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រៀបចំនិងហ្វឹកហ្វឺនវគ្គនាយទាហានសកម្មជំនាន់ទី២៥ ដែលមានរយៈពេលសិក្សា៤ឆ្នាំ ក្នុងឆ្នាំសិក្សា២០២៣ នៅសាលានាយទាហានសកម្ម (ត្នោតពង) ។

**ប្រការ៣ ..**

បេក្ខជនទាំងពីរភេទ ត្រូវជ្រើសរើសពីចំណោមនិស្សិត សិស្ស ដែលស្ម័គ្រចិត្តចូលបម្រើការងារក្នុងក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ត្រូវមានលក្ខណសម្បត្តិដូចតទៅ៖

ក- សញ្ជាតិខ្មែរ

ខ- មានអាយុពី ១៨ឆ្នាំ ដល់ ២៥ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យសុំចុះឈ្មោះចូលប្រឡង

គ- មានកាយសម្បទាគ្រប់គ្រាន់តាមតម្រូវការ ដើម្បីបំពេញមុខងារ

ឃ- មិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោស

ង- មានសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ

ច- បុរសមានកម្ពស់ ១៦០ស.ម និងនារីមានកម្ពស់ ១៥០ស.ម ឡើងទៅ

បេក្ខជនត្រូវមកទំនាក់ទំនងដាក់ពាក្យសុំចុះឈ្មោះចូលប្រឡង នៅសាកលវិទ្យាល័យការពារជាតិ និងបណ្ដាយោធភូមិភាគទី១ យោធភូមិភាគទី២ យោធភូមិភាគទី៣ យោធភូមិភាគទី៤ និងយោធភូមិភាគទី៥ ។

**ប្រការ៤ ..**

បេក្ខជនទាំងពីរភេទ ត្រូវគោរពយ៉ាងម៉ឺងម៉ាត់ តាមល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែង ក្នុងកិច្ចសន្យាស្ម័គ្រចិត្តចូលបម្រើការងារក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ។

**ប្រការ៥ ..**

សិស្សនាយទាហានសកម្មពេលចូលសិក្សាដំបូង ត្រូវបានបំពាក់ឋានន្តរសក្តិជានាយចំណង់ និងត្រូវបានដំឡើងឋានន្តរសក្តិជា **អនុសេនីយ៍ត្រី** ដល់កម្មសិក្សាការីបានប្រឡងបញ្ចប់វគ្គជាប់ជាស្ថាពរ ។

ពេលចេញពីសាលា ត្រូវបំពេញភារកិច្ចតាមបណ្ដាកងឯកភាព នៃកងយោធពលខេមរភូមិន្ទ រយៈពេល៦ខែ ប្រសិនបើអនុវត្តការងារល្អ និងគ្មានទណ្ឌកម្មផ្នែកវិន័យ នឹងត្រូវបានដំឡើងឋានន្តរសក្តិជា **អនុសេនីយ៍ទោ** ដោយស្វ័យប្រវត្តិ ។

ចំពោះកម្មសិក្សាការីដែលប្រឡងធ្លាក់មិនត្រូវបាន ដំឡើងឋានន្តរសក្តិឡើយ លុះត្រាតែបានចេញទៅអនុវត្តការងារតាមបណ្ដាកងឯកភាព នៃកងយោធពលខេមរភូមិន្ទ បានរយៈពេល៦ខែសិន ព្រមទាំងមានមូលវិចារបញ្ជាក់ពីវិន័យការងារនិងចរិយាមារយាទល្អត្រឹមត្រូវ ពីនាយក ឬមេបញ្ជាការ របស់ខ្លួនទើបអាចដំឡើងឋានន្តរសក្តិជាអនុសេនីយ៍ត្រី ។

**ប្រការ៦ ..**

អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ នាយក នាយកដ្ឋានបុគ្គលិក អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន និងមេបញ្ជាការកងឯកភាពដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ[illegible] ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា ទៀ-បាញ់

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងយុត្តិធម៌
-ក្រសួងអប់រំ យុវជន និងកីឡា
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចពិជ័យសេនា ទៀ បាញ់
-ខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន
-ដូចប្រការ៦
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ